**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ២១៩ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងទុនវិនិយោគ របស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA)**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញកិច្ចព្រមព្រៀងសម្បទានរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៩៥
- បានឃើញកិច្ចព្រមព្រៀងសម្បទានបន្ថែមលើកទី១ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៧
- បានឃើញកិច្ចព្រមព្រៀងសម្បទានបន្ថែមលើកទី២ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩
- បានឃើញកិច្ចព្រមព្រៀងសម្បទានបន្ថែមលើកទី៣ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០០
- បានឃើញកិច្ចព្រមព្រៀងសម្បទានបន្ថែមលើកទី៤ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០១
- បានឃើញកិច្ចព្រមព្រៀងសម្បទានបន្ថែមលើកទី៥ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៣
- បានឃើញកិច្ចព្រមព្រៀងសម្បទានបន្ថែមលើកទី៦ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៦
- យោងតាមការចាំបាច់



www.pheakdeylaw.com

### សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងទុនវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១.ឯកឧត្តម | **យឹម ឈុលឡា** | ទេសរដ្ឋមន្ត្រីនិងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ប្រធាន |
| ២.ឯកឧត្តម | **ឌី តាយី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣.ឯកឧត្តម | **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤.ឯកឧត្តម | **គង់ វិបុល** | អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៥.ឯកឧត្តម | **ឃុត ចាន់ដារ៉ា** | ទីប្រឹក្សា និងនាយករងខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ៦.ឯកឧត្តម | **ខា ពៅ** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧.ឯកឧត្តម | **ហាក់ សុខហេង** | អគ្គលេខាធិការរងក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក។ |

**ប្រការ ២.-**

គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងទុនវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) មានភារកិច្ចដូចខាងក្រោម៖

- សិក្សាលំអិតលើកិច្ចព្រមព្រៀងសម្បទានទាំងអស់ ដែលរាជរដ្ឋាភិបាលបានចុះហត្ថលេខាជាមួយក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ដើម្បីផ្ទៀងផ្ទាត់ការអនុវត្តគម្រោងចាប់តាំងពីពេលចាប់ផ្តើមរហូតដល់ពេលបច្ចុប្បន្ន
- ត្រួតពិនិត្យ និងវាយតម្លៃការវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ទៅលើព្រលានយន្តហោះអន្តរជាតិទាំងបី រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ
- ត្រួតពិនិត្យបញ្ជីគណនេយ្យរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) ដើម្បីទទួលបានទិន្នន័យវិនិយោគ និងកំណត់ឱ្យបានត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុ រួមទាំងការគណនាអត្រាចំណូល (IRR) របស់ក្រុមហ៊ុន
- អនុវត្តភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ ៣.-**

គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងការវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញ ដើម្បីពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងផ្តល់យោបល់តាមការចាំបាច់។

គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងការវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារ តាមការចាំបាច់។

**ប្រការ ៤.-**

សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន។



www.pheakdeylaw.com

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com